# និរន្តរភាពវិស័យជលផលនៅក្នុងបឹងទន្លេសាប

## FHI 360/Global FISH Alliance

ព្រឹត្តិប័ត្រប្រចាំ ខែមេសា ឆ្នាំ២០១៣

## សន្សំប្រាក់សំរាប់ក្រុមល្បាតសហគមន៍

បន្ទាប់ពីទទួលបានការគាំទ្រពីសមាគមន៍ភ្នំនាងកង្រី (PNKA) អស់រយៈពេលជាងប្រាំពីឆ្នាំមក សហគមន៍ភូមិកំពង់ត្រឡាចលើ មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការផ្គត់ផ្គង់ថវិកា សំរាប់ក្រុមល្បាតសហគមន៍។ លោក គេន សាវេត ប្រធានសហគមន៍កំពង់ត្រឡាចលើ បាននិយាយថា "ចាប់តាំងពីសមាគមន៍ភ្នំនាងកង្រី ផ្តល់ការគាំទ្រដល់សហគមន៍របស់យើង ពួកយើងបានក្រោកឈរឡើង។ ឥឡូវនេះ យើងអាចដាក់ថវិកាមួយចំនែកសម្រាប់សកម្មភាពយាមល្បាតដែលបានអនុញ្ញាតឱ្យយើងការពារធនធានធម្មជាតិនៅក្នុងសហគមន៍របស់យើង។ "

ជិតប្រាំពីរឆ្នាំមកហើយ ដែលសហគមន៍កំពង់ត្រឡាចលើ បានបង្កើតក្រុមមួយហៅថា **"ក្រុមសន្សំ"** ដែលបានប្រមូលថវិកាសម្រាប់គាំទ្រដល់ការកសាងសមត្ថភាពនិងសន្តិសុខស្បៀង។ ក្រុមនេះត្រូវបានគាំទ្រថវិកាដោយ សមាគមន៍ភ្នំនាងកង្រី ដើម្បីធ្វើជាទុនសំរាប់សហគមន៍របស់ពួកគេ។ សហគមន៍បានវិនិយោគប្រាក់ទាំងនេះនៅក្នុងគណនីមួយជាមួយនឹងអត្រាការប្រាក់ពីរភាគរយ។

សហគមន៍កំពង់ត្រឡាចលើក៏បានទទួលថវិការបដិភាគពីសំណាក់ប្រជានេសាទដែលមកធ្វើសកម្មភាពនេសាទនៅក្នុងតំបន់របស់ពួកគេ។ លើសពីនេះទៅទៀត រាល់អ្នកភូមិដែលមានការងារនៅក្នុងសហគមន៍នេះបានរួមចំនែក 500 រៀលក្នុងមួយខែដើម្បីការពារធនធានធម្មជាតិនៅក្នុងតំបន់របស់ពួកគេ។

សមាជិកសហគមន៍ត្រូវជួបប្រជុំគ្នាម្តងក្នុងមួយខែ ដើម្បីពិភាក្សាអំពីការប្រើប្រាសថវិកាសហគមន៍។ ប្រាក់ទាំងនេះ ត្រូវបានប្រើសម្រាប់ល្បាតសហគមន៍ ធ្វើអោយជីវភាពសហគមន៍មានភាពប្រសើរឡើង ជួយចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ និងការគាំទ្រដល់អ្នកជិតខាងរបស់ពួកគេប្រសិនបើចាំបាច់។

លោក អ៊ុក សាម៉េត នាយកប្រតិបត្តិសមាគមន៍ភ្នំនាងកង្រីនិយាយថា "ខ្ញុំពិតជាមានមោទនភាព ចំពោះការងាររបស់សហគមន៍កំពង់ត្រឡាចចំពោះការធ្វើការងារកន្លងមកណាស់។ ពួកគេខ្លាំងមានលទ្ធភាពឈរដោយខ្លួនឯងបានសមាគមន៍ភ្នំនាងកង្រី នឹងបន្តតាមដាននិងគាំទ្រដល់សហគមន៍កំពង់ត្រឡាចលើ ដើម្បីធានាបាននូវការងារដ៏មានតម្លៃរបស់ពួកគេនៅតែបន្តដោយរលូន។ "

"ខ្ញុំបានសង្កេតឃើញថា តំបន់ដែលនៅជិតសហគមន៍របស់ខ្ញុំគ្មានដើមឈើ ខណៈពេលដែលសហគមន៍របស់ខ្ញុំនៅមានដើមឈើច្រើន" លោកសាវ៉េតនិយាយ ។ សហគមន៍កំពង់ត្រឡាចលើ ខ្លាំង និងបានធ្វើការរួមគ្នាដើម្បីការពារធនធានធម្មជាតិ សម្រាប់ចំនូលរបស់គ្រួសារ និងសម្រាប់អ្នកជំនាន់ក្រោយរបស់ពួកគេ។ លោកបាននិយាយថា "បើគ្មានការគាំទ្រពីសមាគមន៍ភ្នំនាងកង្រី និងអាជ្ញាធរមូលដ្ឋានទេ សហគមន៍របស់ខ្ញុំនឹងមិនទទួលបានជោគជ័យដូចសព្វថ្ងៃនេះដែរ។" លោក សាវ៉េត និងសមាជិកសហគមន៍ទាំអស់មានការដឹងគុណ និងអរគុណយ៉ាងខ្លាំងចំពោះ សមាគមន៍ភ្នំនាងកង្រី និងអាជ្ញាធរមូលដ្ឋាន នៅក្នុងសហគមន៍របស់លោកដែលបានជួយគាំទ្រឱ្យលោក និងសមាជិកសហគមន៍ បានធ្វើសកម្មភាពរបស់ខ្លួននៅក្នុងសហគមន៍។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមទាក់ទង លោក គេន សាវ៉េត ប្រធានសហគមន៍កំពង់ត្រឡាចលើ។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh
E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313

# គំរោងពិនិត្យតាមដានផលចាប់ត្រីរបស់ប្រជានេសាទនៅជុំវិញបឹងទន្លេសាប

បឹងទន្លេសាប គឺជាបឹងទឹកសាបដែលធំជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ វាគឺជាអាងស្តុកទឹកធម្មជាតិ និងជាជំរកដ៏សំខាន់សម្រាប់ត្រី ព្រមទាំងជួយទ្រទ្រង់ជីវភាពរស់នៅសម្រាប់ជីវិតរស់នៅរាប់លាននាក់ ជាពិសេស អ្នកដែលនៅជុំវិញបឹងនេះ។ ធនធានជលផល គឺជាជម្រើសមួយដ៏សំខាន់ក្នុងការចិញ្ចឹមជីវិត ជាពិសេសសម្រាប់ប្រជាជន ដែលរស់នៅក្នុងបណ្តាខេត្តជុំវិញបឹងទន្លេសាប។

ដើម្បីទ្រទ្រង់ធនធានជលផលនេះ នៅខែឧសភា ឆ្នាំ 2011 រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានចេញបទបញ្ជាថ្មីៗ ស្តីពីវិធានការវិន័យ ដើម្បីកាត់បន្ថយសកម្មភាពនេសាទខុសច្បាប់ នៅក្នុងខេត្តចំនួនប្រាំមួយ នៅជុំវិញបឹងទន្លេសាប។ ឡូត៍នេសាទទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប ត្រូវបានដកហូតវិញ និងចាត់វិធានការមួយចំនួន ដើម្បីអនុញ្ញាតឱ្យតំបន់ទាំងនេះក្លាយជាតំបន់សហគ្រប់គ្រង ដោយស្ថាប័នពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ក្នុងគោលបំណងដើម្បីអភិរក្សត្រី និងធនធានជីវចំរុះក្នុងប្រទេសកម្ពុជា។

អាជ្ញាធរទន្លេសាប (TSA) ទទួលការឧបត្ថម្ភថវិកាដោយគណៈកម្មការទន្លេមេគង្គ (MRC) បានបង្កើតនូវគំរោងត្រួតពិនិត្យតាមដានផលផលចាប់ត្រីរបស់ប្រជានេសាទ នៅជុំវិញបឹងនេះ។ គោលបំណងនៃគម្រោងនេះគឺ ដើម្បីកំណត់សូចនាករទិន្នផលត្រី ដែលទាក់ទងទៅនឹងការចាប់ ការគ្រប់គ្រង និង ប្រភេទផ្សេងៗគ្នារបស់ត្រី ហើយនិងនិន្នាការនៃធនធានជលផលនៅតាមខេត្តនិមួយៗ។ ការសិក្សានេះ គឺជាផ្នែកមួយនៃការត្រួតពិនិត្យតាមដាន ផលចាប់ត្រីប្រចាំថ្ងៃរបស់ប្រជានេសាទ នៅក្នុងអាងទឹកទន្លេមេគង្គក្រោម។ ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលសិក្សានេះ រួមចំណែកដល់ការបកស្រាយនៃស្ថានភាព និងនិន្នាការនៃការចាប់ត្រី ក៏ដូចជាការផ្តល់នូវមធ្យោបាយដ៏មានប្រសិទ្ធិភាពបន្ថែមទៀតទៅលើការតាមដាន និងការវាយតំលៃនៃប្រសិទ្ធភាពសកម្មភាពគ្រប់គ្រង និងការអភិវឌ្ឍអាងទន្លេមេគង្គ។

គំរោងពិនិត្យតាមដានផលចាប់ត្រីរបស់ប្រជានេសាទ ត្រូវបានធ្វើឡើងនៅក្នុងបណ្តាខេត្តចំនួនប្រាំនៅជុំវិញបឹងទន្លេសាបរួមមាន ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេតកំពង់ធំ ខេត្តបាត់ដំបង និងខេត្តសៀមរាប។

បន្ទាប់ពីការពិនិត្យតាមដាន លទ្ធផលបានបង្ហាញថា ផលនេសាទសរុបរបស់ប្រជានេសាទទាំង 15 នាក់មកពីខេត្តទាំងប្រាំ សម្រាប់រយៈពេល 11 ខែនេះគឺបានចំនួន 66,836 គីឡូក្រាម និងមានត្រីចំនួន 99 ប្រភេទផ្សេងៗគ្នា ត្រូវបានកំណត់នៅក្នុងកំណត់ត្រារបស់ប្រជានេសាទ។ ជាទូទៅ ផលចាប់សរុបមានលក្ខណៈផ្លាស់ប្តូរ ទៅតាមទីតាំងភូមិសាស្ត្រ ប៉ុន្តែតំបន់ដែលត្រួតត្រាដោយខេត្តបាត់ដំបងមានចំនួន 27% នៃទិន្នន័យសរុបដែលត្រូវបានកត់ត្រា អមដោយខេត្តកំពង់ធំដែលមានចំនួន 26% នៃទិន្នន័យសរុបត្រូវបានកត់ត្រាទុក ប្រមូលទិន្នន័យដែលតិចជាងគេបំផុតគឺមានចំនួន10% មកពីខេត្តសៀមរាប។ ប្រភេទពូជត្រីសំខាន់ៗនៅក្នុងការចាប់មាន ត្រីច្រកែង10% មានត្រីរៀលតុប 9% និងត្រីក្រុស 7% ។

ការចាប់ត្រីជាមធ្យម នៅជុំវិញបឹងទន្លេសាប ដែលប្រមូលបានពីតំបន់ត្រួតពិនិត្យទាំងប្រាំ មានចំនួន14 គីឡូក្រាមក្នុងមួយថ្ងៃ។ ផលនេសាទត្រីប្រចាំថ្ងៃដោយប្រើលប ត្រូវបានគេកត់ត្រា ពីខែមិថុនាដល់ខែវិច្ឆិកា។ ការនេសាទជាមធ្យមសម្រាប់ឧបករណ៍លប មានចំនួន6,65 គីឡូក្រាមក្នុងមួយថ្ងៃ។ មងអាចចាប់ប្រភេទត្រីជាច្រើនដែលមានចំនួន 98% នៃផលនេសាទសរុប ខណៈពេលដែលលបចាប់បានយ៉ាងហោចណាស់បាន 2% ។

ការពនិត្យតាមដានផលចាប់ត្រី របស់ប្រជានេសាទនៅក្នុងបឹងទន្លេសាប មានសារៈសំខាន់ នៅក្នុងការបង្កើតឡើងនូវមូលដ្ឋានទិន្នន័យ និងពត៌មានដែលចាំបាច់ ដើម្បីជួយឱ្យយល់ពីនិន្នាការ នៃអត្រាចាប់ត្រីដោយប្រជានេសាទ នាពេលបច្ចុប្បន្ននេះ។(ដកស្រង់ចេញពី របាយការណ៍ស្តីពីការពិនិត្យតាមដានផលចាប់ត្រីរបស់ប្រជានេសាទនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប នៃប្រទេសកម្ពុជា របស់អាជ្ញាធរទន្លេសាប។)

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះ សូមទាក់ទងលោក ភេម ស៊ា អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្មនិងអភិរក្ស។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh

E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313

# សមាគមន៍ភ្នំនាងកង្រី៖ អភិវឌ្ឍន៍សហគមន៍និងអភិរក្សធនធានធម្មជាតិ

សមាគមន៍ភ្នំនាងកង្រី គឺជាអង្គការមិនមែនរដ្ឋាភិបាល និងមិនមែនជាគណបក្សនយោបាយ។ សមាគមន៍ភ្នំនាងកង្រីត្រូវបានបង្កើតឡើងនៅឆ្នាំ1993 និងបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ នៅខែមីនា ឆ្នាំ1994។ នាយកប្រតិបត្តិបច្ចុប្បន្ន លោក អ៊ុក សាម៉េត ដែលលោកធ្លាប់បានធ្វើការជាមួយអង្គការនេះចាប់តាំងពីឆ្នាំ 2003 មកម្លេះ។

គោលបំណងនៃការបង្កើតសមាគមន៍មួយនេះគឺដើម្បីកែលម្អវិស័យអប់រំរបស់កុមារនៅក្នុងប្រទេសកម្ពុជាដោយផ្តោតលើការជួយ ជំរុញឲ្យកុមារទទួលបានការសិក្សា ដោយរៀបចំបណ្ណាល័យ និងក្រុមប្រឹក្សាសាលាសម្រាប់កុមារី ដែលរស់នៅក្នុងតំបន់ដាច់ស្រយ៉ាល ដើម្បីឲ្យពួកគេ អាចទទួលបាននូវការសិក្សាអប់រំរហូតដល់ថ្នាក់វិទ្យាល័យ។

ទិសដៅជាយុទ្ធសាស្រ្តសម្រាប់ 2013-2015 របស់សមាគមន៍ភ្នំនាងកង្រីរួមមាន៖ ការធ្វើការងារជាមួយសហគមន៍ជនបទក្រីក្រ ដើម្បីជួយដល់កុមារក្រីក្រឲ្យមានលទ្ធភាពចូលរៀននៅថ្នាក់មូលដ្ឋាន ថែទាំសុខភាពបឋមជាមួយនឹងការផ្តោតជាសំខាន់នៅលើទឹកស្អាត និងអនាម័យ(លាងសម្អាត) អាហាររូបត្ថម្ភ និងការកាត់បន្ថយអត្រាស្លាប់របស់កុមារ ការគ្រប់គ្រងធនធានធម្មជាតិ(NRM) រួមទាំងសហគមន៍ព្រៃឈើនិងនេសាទ(CFF) ការចូលរួមនៅក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងការពង្រឹងសមត្ថភាពនិងការអភិវឌ្ឍ ដោយរៃអង្គាសមូលនិធិដើម្បីបង្កើតប្រភពប្រាក់ចំណូលប្រកបដោយនិរន្តរភាព។

សមាគមន៍ភ្នំនាងកង្រីបានទទួលការគាំទ្រមូលនិធិពីម្ចាស់ជំនួយមួយចំនួនរួមមាន អង្គការកិច្ចសហប្រត្តិបត្តការកម្ពុជា-អូស្រ្តាលី អង្គការខនសឺនវើលវ៉ាល (Concern Worldwide) អង្គការសង្គ្រោះនិងការអភិវឌ្ឍន៍អន្តរជាតិ(IRD) អង្គការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live&Learn) អង្គការភិបផលអីននិត (People in Need) អង្គការភាពជាដៃគូ សង្គមស៊ីវិល កម្ពុជា (CCSP) និងអង្គការសេវាស្ម័គ្រចិត្ត ក្រៅប្រទេស (VSO) ។

សមាគមន៍ភ្នំនាងកង្រីបានទទួលនូវលទ្ធផលដូចខាងក្រោម:

1. ក្រុមគោលដៅទទួលបានចំណេះដឹងនិងជំនាញនៃការទាក់ទងទៅនឹងការចិញ្ចឹមមាន់ រៀបចំសួននៅផ្ទះ និងដាំបន្លែ។
2. ក្រុមគោលដៅបានបង្កើតផែនការអាជីវកម្ម និង ផែនការសេដ្ឋកិច្ចគ្រួសារ។
3. ក្រុមគោលដៅទទួលបានចំណេះដឹងអំពីការផ្លាស់ប្តូរនៃតម្លៃទីផ្សារ ហើយពួកគេមានការយល់ដឹងពីតម្រូវការផលិតផលសម្រាប់ទីផ្សារ។
4. សមាគមន៍គណ:កម្មាធិភូមិ (VCA) នៃធនាគារស្រូវបានបង្កើតចំនេះដឹង ដើម្បីគ្រប់គ្រងគម្រោងធនាគារស្រូវ។ សមាជិកនៃគម្រោងធនាគារស្រូវអាចខ្ចីនិងសង 95% ដល់ 100% ក្នុងកំឡុងពេលមួយឆ្នាំម្តង។
5. ក្រុមគោលដៅដែលបានបង្កើតឱ្យមានប្រព័ន្ធមួយសម្រាប់ការបែងចែកសត្វចិញ្ចឹម។ ឧទាហរណ៍ នៅពេលដែលគោបានកូនគ្រួសារថែរក្សាបានរក្សាទុកកូនគោ ហើយមេគោត្រូវបានផ្លាស់ទីនៅលើទៅគ្រួសារផ្សេងទៀត។ កសិករក៏ត្រូវបានគេបានបង្ហាញពីរបៀបធ្វើជីកំប៉ុសពីកាកសំណល់សត្វនិងកាកសំណល់សរីរាង្គផ្សេងៗ។
6. សមាគមន៍គណ:កម្មាធិភូមិសម្រាប់ធនាគារហិរញ្ញវត្ថុ មានដើមទុនដើម្បីផ្តល់នូវប្រាក់កម្ចីដល់សមាជិករបស់ខ្លួនសម្រាប់ប្រកបអាជីវកម្ម និងផលិតផលកសិកម្ម។
7. សមាគមន៍គណ:កម្មាធិភូមិសម្រាប់សុខភាព មានប្រព័ន្ធនៅតាមទីកន្លែងដើម្បីជួយដល់សមាជិកដែលឈឺ និងរងរបួសឲ្យមានលទ្ធភាពទទួលការព្យាបាលនៅមណ្ឌលសុខ។
8. សមាគមន៍គណ:កម្មាធិភូមិ សម្រាប់មេត្តាធម៌សង្គម បានផ្តល់ជំនួយដល់ចាស់ជរា កុមារ និងពិធីបុណ្យសព។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមទាក់ទងលោក អ៊ុក សាម៉េត នាយកប្រតិបត្តិសមាគមន៍ភ្នំនាងកង្រី។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh
E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313

# វារីវប្បកម្មគម្រោងអង្គការ JICA

អង្គការទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)បានធ្វើការសហការណ៍ជាមួយរដ្ឋបាលជលផល បានគាំទ្រដល់គម្រោង វារីវប្បកម្មដែលមានឈ្មោះថា “**បង្កើនផលិតភាព នឹង ផ្សព្វផ្សាយវារីវប្បកម្មទឹកសាប**” នៅក្នុងខេត្តសៀមរាប ដែលមានរយៈពេល 4ឆ្នាំ ចាប់តាំងពីឆ្នាំ 2011រហូតមកដល់បច្ចុប្បន្ននេះ ដើម្បីជួយបង្កើនលទ្ធភាពនៃការផលិត និងការអនុវត្តន៍នៃវារីវប្បកម្មទឹកសាប។ រដ្ឋបាលជលផលជាអ្នកអនុវត្តន៍លើគំរោងនេះផងដែរ។

អង្គការទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ធ្លាប់បានផ្តល់គម្រោង “បង្កើនផលិតភាព នឹង ផ្សព្វផ្សាយវារីវប្បិកម្ម ” ដែលនេះជាជំហានទីមួយ បានធ្វើនៅក្នុងខេត្តកំពត និង ខេត្តកំពង់សោម មុនពេលធ្វើសកម្មភាពនៅខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តពោធិសាត់ដែលជាជំហានទី2 របស់គំរោងនេះ។ គំរោងបង្កើនផលិតភាព នឹង ផ្សព្វផ្សាយវារីវប្បកម្មទឹកសាប បានជ្រើសរើសកសិករផលិតពូជត្រីជាលក្ខណ:គ្រួសារដែលមកពី 11ស្រុកជីក្រែង ស្រុកសូត្រនិគមន៍ ស្រុកបាគង ស្រុកពួក ស្រុកអង្គរជុំ ស្រុកអង្គរធំ ស្រុកវារិន និង ស្រុកបន្ទាយស្រី ដោយរដ្ឋបាលជលផលជាអ្នកផ្តល់នូវវគ្គបណ្តុះបណ្តាលដល់ពួកគាត់។ ក្នុងគំរោង បង្កើនផលិតភាព នឹង ផ្សព្វផ្សាយវារីវប្បកម្មទឹកសាប របស់JICA បានធ្វើកសិដ្ឋានផលិតកូនត្រីចំនួន 11 កន្លែង។ បន្ទាប់ពីកសិករដែលបានទទួលនូវវគ្គបណ្តុះបណ្តាល កសិករអាចផលិតកូនត្រី ដោយខ្លួនឯងបាន នឹង អាចចែកចាយកូនត្រីទៅដល់កសិករដទៃទៀត បានទៅដល់ពី 30 ទៅ 40 គ្រួសារ ។

ក្រោយពីគំរោងនេះមានដំណើរការមួយរយ: គេសង្កេតឃើញថា កសិករអាចផលិត នឹង ចិញ្ចឹមកូនត្រីបានដោយខ្លួនឯង។ ហើយម្យ៉ាងវិញទៀតពួកគាត់បានបង្កើតជាបណ្តាញផលិតកូនត្រីប្រចាំខេត្ត ដែលអាចឲ្យពួកផ្លាស់ប្តូរចំនេះដឹងពីគ្នាទៅវិញទៅមក នឹង អាចជួយគ្នាក្នុងក្រុមបាន។ មិនតែប៉ុណ្ណោះ ជីវភាពរបស់ប្រជាកសិករ ក៏មានភាពប្រសើរជាងមុនផងដែរ ។

*ពត៌មានបន្ថែមទាក់ទងនឹងការងារនេះសូមទាក់ទងលោក ព្រិន សារិន នាយខណ្ឌរដ្ឋបាលជលផលសៀមរាប។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh
E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313